**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ: ០១១៨.....ប្រ.ក... ប.ស្ក

# ប្រកាស
## ស្ដីពី
## ការទទួលស្គាល់ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ «អណ្ដូងទឹក» ក្នុងឧទ្យានជាតិបុទុមសាគរ ស្ថិតនៅភូមិប្រៃ ភូមិជីត្រេះ ភូមិតាអុក ភូមិប្រទាល និងភូមិតាមាឃ ឃុំអណ្ដូងទឹក ស្រុកបុទុមសាគរ ខេត្តកោះកុង

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៥អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញលិខិតចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ ស្ដីពីការស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ «អណ្ដូងទឹក»
- យោងតម្រូវការចាំបាច់

## សម្រេច

**ប្រការ១._** ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ«អណ្ដូងទឹក» ក្នុងឧទ្យានជាតិបុទុមសាគរ ស្ថិតក្នុងភូមិសាស្ត្រ ភូមិប្រៃ ភូមិជីត្រេះ ភូមិតាអុក ភូមិប្រទាល និងភូមិតាមាឃ ឃុំអណ្ដូងទឹក ស្រុកបុទុមសាគរ ខេត្តកោះកុង។

**ប្រការ២._** សហគមន៍តំបន់ការពារធម្មជាតិ «អណ្ដូងទឹក» ក្នុងឧទ្យានជាតិបុទុមសាគរ មានផ្ទៃដីទំហំ ១២៨៦ហិកតា ដូចមានផែនទីជាឧបសម្ព័ន្ធកំណត់ដោយបណ្ដាចំណុចគោលដែលមាននិយាមកា ដូចក្នុងតារាងខាងក្រោម៖

| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| A | ៣២៨៦៩០ | ១២២៨៦៨៦ | K | ៣៣១៧២៨ | ១២៣០៥៨៥ |
| B | ៣២៨៨៥៧ | ១២២៨៨២១ | L | ៣៣១៦៣៤ | ១២៣១០០៩ |
| C | ៣២៩៣៨៣ | ១២២៨៨៣៣ | M | ៣៣១៧៧៦ | ១២៣១៤៧៥ |
| D | ៣២៩៥៣៣ | ១២២៨៩៧៥ | N | ៣៣-៧៨៦ | ១២៣១៧៩៦ |
| E | ៣៣០១០៦ | ១២២៩៤១៩ | O | ៣៣១៧៩៨ | ១២៣២២២៨ |
| F | ៣៣០២៨៩ | ១២២៩៤៦០ | P | ៣៣២២៤៧ | ១២៣២៤៤៣ |
| G | ៣៣០៥០៧ | ១២២៩៥៦៦ | Q | ៣៣១៩៧៦ | ១២៣៣៦៣០ |
| H | ៣៣០៧៤៥ | ១២២៩៥៨៤ | R | ៣៣៤៥៤០ | ១២៣៣៤៩១ |
| I | ៣៣០៩៨០ | ១២២៩៦៦៩ | S | ០៣២៩៤៤០ | ១២២៦៩៥៤ |
| J | ៣៣១៤៩៥ | ១២៣០១០២ | | | |

**ប្រការ៣._** សហគមន៍តំបន់ការពារធម្មជាតិ«អណ្តូងទឹក»ក្នុងឧទ្យានជាតិបុទុមសាគរ ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ«អណ្តូងទឹក» ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ៤._** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥._** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន ឧទ្ទកាល័យាដ្ឋមន្ត្រី អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តកោះកុង នាយកឧទ្យានជាតិបុទុមសាគរ និងសហគមន៍តំបន់ការពារធម្មជាតិ«អណ្តូងទឹក» ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មករា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

<u>កន្លែងទទួល</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តកោះកុង
- ដូចប្រការ៥ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ